# ពុទ្ធិកសិក្សា

នៅប្រទេសកម្ពុជា

www.elibraryofcambodia.org

**L'enseignement du Buddhisme au Cambodge**

www.elibraryofcambodia.org

# ពុទ្ធិកសិក្សាសខ្មែរ

ផ្សាយចេញអំពី

## អគ្គាធិការដ្ឋាននៃពុទ្ធិកសិក្សាក្នុងព្រះរាជអាណាចក្រ

## ទុកជាទីរលឹក

www.elibraryofcambodia.org

ក្នុងឱកាសមហាសន្និបាតធ្វើសន្និសីទទូទៅ
នៃពុទ្ធិកសមាគមពិភពលោក

នៅក្រុងភ្នំពេញ ប្រទេសកម្ពុជា

តាំងពីថ្ងៃអាទិត្យ ៥ កើត ដល់ ១៤ កើត ខែកត្តិក ឆ្នាំឆ្លូវត្រីស័ក ព.ស. ២៥០៤

គឺតាំងពីថ្ងៃទី ១២ ដល់ទី ២២ ខែវិច្ឆិកា គ.ស. ១៩៦១

www.elibraryofcambodia.org




www.elibraryofcambodia.org

គ្រឹះស្ថាន ពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត
ព.ស. ២៤៥៧ - គ.ស. ១៩១៤

www.elibraryofcambodia.org

# អំពីពុទ្ធិកសិក្សានៅប្រទេសកម្ពុជា

ការរៀបចំពុទ្ធិកសិក្សានៅប្រទេសកម្ពុជា អាចឲ្យសមណសិស្សគ្រប់ យកបំណេះវិជ្ជាកាន់តែទូលំទូលាយឡើង ទាំងខាងផ្លូវសាសនា ទាំងខាងផ្លូវលោក ឲ្យមានទស្សនៈតែមួយបែបដូចគ្នាចំពោះព្រះពុទ្ធសាសនា និងការអនុវត្តន៍ត្រូវគ្នានូវធម៌វិន័យដែលព្រះបរមគ្រូទ្រង់បានត្រាស់ទុកមក ។ រីឯការអប់រំសមណសិស្សតាមទម្រង់តែមួយនេះ ដែលបានទទួលការវិវឌ្ឍន៍ចំរើនរីកសាយទូទៅក្នុងប្រទេស គឺដោយសារតែព្រះបរមរាជូបត្ថម្ភនៃព្រះមហាក្សត្រ ជាពិសេស តាំងពីរាជ្យព្រះបាទសម្តេចព្រះ **អង្គឌួង** រៀងមក ។ ព្រះរាជាអង្គនេះទ្រង់ជាកវីជាតិ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ទ្រង់បានចាត់ការកសាងវត្តវិហារជាច្រើននៅក្រុងឧដុង្គ ទ្រង់បានបង្កើតការសិក្សាព្រះត្រៃបិដក ព្រមទាំងទ្រង់បានបង្រៀនបាលីផ្ទាល់ព្រះអង្គផង នៅពេលយប់ ៗ ក្នុងរដូវវស្សា ។

www.elibraryofcambodia.org

របៀបការសិក្សាតាំងពីសម័យនោះ រហូតមកដល់ដើមគ្រិស្តសតវត្សរ៍ទី ២០ ជារបៀបទន្ទេញចាំមាត់នៅឡើយ ។ ឯការប្រឡង យូរ ៗ ទើបមានម្តង តាមព្រះរាជានុញ្ញាតនៃព្រះករុណាជាម្ចាស់ជីវិតលើត្បូង បន្ទាប់អំពីសេចក្តីស្នើរបស់គណៈសង្ឃ មានឈ្មោះថា «**ប្រឡងដេញប្រយោគ**» ដែលមានតែវិញ្ញាសាសួរផ្ទាល់មាត់ឲ្យប្រែពីបាលីមកជាភាសាខ្មែរតែប៉ុណ្ណោះ ។ បេក្ខសមណៈណា អាចប្រែប្រយោគដែលដកស្រង់ចេញពីគម្ពីរធម្មបទចំនួនបីប្រយោគបាន តាមចំរវេលាកំរិតមួយម៉ោងក្នុងមួយប្រយោគ ចំនួនបាលី ២ សន្លឹកស្វ័កដែក សមណៈនោះត្រូវបានទទួលឋានៈជា « **មហាបីប្រយោគ** » ។

ហេតុសមណៈណាដែលជាប់ជា **«មហាបីប្រយោគ»** ហើយអាចសុំចូលប្រឡងយកឋានៈជា **«មហាបួនប្រយោគ»** រហូតដល់ឋានៈជា **«មហាប្រាំបួនប្រយោគ»** តទៅទៀតបាន ។

កាលប្រទេសខ្មែរនៅក្នុងអាណាព្យាបាលបារាំង (សន្ធិសញ្ញាចុះថ្ងៃទី ១១ សីហា ១៨៦៣) ពុទ្ធិកសិក្សាមានការរៀបចំជាផ្លូវការក្នុងពេលដំណាលគ្នានឹងការបង្កើតជាលើកដំបូងនូវសាលាបារាំងខ្មែរ ក្នុងព្រះរាជអាណាចក្រ ៖

– គ. ស. ១៩១៤ បានបង្កើតសាលាពុទ្ធិកសិក្សាមួយមានឈ្មោះថា **«សាលាបាលី»** ដែលខាងក្រោយមកហៅថា **«សាលាបាលីជាន់ខ្ពស់»** ។

– តាំងពី គ. ស. ១៩៣៣ មក មានបង្កើតសាលាបាលីរងទូទៅក្នុងប្រទេស ។ ក្នុងចំណោមសមណសិស្ស ដែលចេញពីសាលាពុទ្ធិកសិក្សាមានសញ្ញាប័ត្រសាលាបាលី - សាលាបាលីជាន់ខ្ពស់ ឬ វិញ្ញាបនប័ត្រសាលាបាលីរង, ភាគខ្លះបានធ្វើជាអាចារ្យបង្រៀនក្នុងសាលាបាលីរង ភាគខ្លះទៀតបង្រៀនកុមារក្នុងសាលាវត្ត ។ ក្នុងប៉ុន្មានឆ្នាំមុននេះ មានកុមារចំនួនប្រហែល ៨១ ០០០ នាក់ បានចូលរៀនតាមប្រពៃណីក្នុងសាលាវត្តទាំងនោះ ។

ក្នុងសម័យដែលប្រទេសខ្មែរបានឋានៈជាប្រទេសឯករាជ្យតាំងពី គ. ស. ១៩៥៣ មក ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម - សីហនុវរ្ម័ន** ទ្រង់មានព្រះរាជបញ្ញត្តិឲ្យចាត់ការរើរៀបចំការសិក្សាខាងព្រះពុទ្ធសាសនានេះជាថ្មី ដើម្បីឲ្យមានដំណើរស្របទៅតាមកាលៈទេសៈ ៖

– បានរៀបចំពុទ្ធិកសិក្សាឲ្យមានភូមិសិក្សា ៣ ផ្នែកគឺ **ពុទ្ធិកឧត្តម-**

www.elibraryofcambodia.org

សិក្សា ពុទ្ធិកមធ្យមសិក្សា និង ពុទ្ធិកបឋមសិក្សា

– បានបង្កើតឲ្យមាន **ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ** សំរាប់ពុទ្ធិកឧត្តមសិក្សា និង **អគ្គាធិការដ្ឋាននៃពុទ្ធិកសិក្សា** ក្នុងព្រះរាជអាណាចក្រ

– បានកែប្រែគម្ពវិធីសិក្សានៅសាលាបាលីជាន់ខ្ពស់ និងសាលាបាលីរង ឲ្យមានមុខវិជ្ជាសំរាប់សិក្សាចំរើនជាងកាលមុនជាច្រើន ហើយបានកែប្រែសាលាបាលីជាន់ខ្ពស់ទៅជា «ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត» សំរាប់ពុទ្ធិក-មធ្យមសិក្សា ទាំងសាលាបាលីរងក៏បានកែប្រែទៅជា «សាលាពុទ្ធិកបឋម-សិក្សា» សំរាប់ពុទ្ធិកបឋមសិក្សាវិញ ។

www.elibraryofcambodia.org

# អគ្គាធិការដ្ឋាននៃពុទ្ធិកសិក្សា

ក្រុមពិនិត្យត្រួតត្រាគ្រឹះស្ថានពុទ្ធិកឧត្តមសិក្សា មធ្យមសិក្សា និង បឋមសិក្សា ដែលបានកើតឡើងតាមព្រះរាជក្រឹត្យ លេខ ៣៤១ ន.ស. ចុះថ្ងៃទី ២០-៦-៥៥ ស្ថិតនៅក្រោមការទទួលខុសត្រូវនៃអគ្គាធិការមួយរូប ដែលជ្រើសយកក្នុងចំណោមព្រះសង្ឃរាជាគណៈ តែងតាំងឡើងដោយព្រះរាជក្រឹត្យ តាមសេចក្ដីស្នើសុំពីរដ្ឋមន្ត្រីក្រសួងធម្មការ និងក្រោយពីសេចក្ដីយល់ព្រមនៃសម្ដេចព្រះសង្ឃនាយកទាំងពីរគណៈ ។

បុគ្គលិកនៅអមអគ្គាធិការនៃពុទ្ធិកសិក្សា មាន :

— អគ្គាធិការរងពីររូប ជ្រើសយកក្នុងចំណោមសាស្ត្រាចារ្យនៃពុទ្ធិកវិទ្យាល័យ ហើយតែងតាំងតាមភូមិភាគ ដោយប្រកាសក្រសួងធម្មការ ក្រោយដែលបានទទួលសេចក្ដីយល់ព្រមពីសម្ដេចព្រះសង្ឃនាយក ទាំងពីរគណៈ

— អធិការប្រចាំខេត្ត និង អធិការរងប្រចាំស្រុក : មុខងារទាំងពីរផ្នែកនេះ តម្រូវតាមលំដាប់ទៅលើលោកគ្រូមេគណ និង លោកគ្រូអនុគណ ។

នៅអមអគ្គាធិការនៃពុទ្ធិកសិក្សា មានទីប្រឹក្សាបច្ចេកទេសមួយរូប ។

តាមព្រះរាជក្រឹត្យលេខ ៧២៨ ន.ស. ចុះថ្ងៃទី ២៨-១១-៥៥ ព្រះតេជព្រះគុណព្រះពោធិវង្ស **ហួត-តាត** ចាងហ្វាងនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ត្រូវបានតាំងជាអគ្គាធិការនៃពុទ្ធិកសិក្សានៃព្រះរាជអាណាចក្រកម្ពុជា ។

www.elibraryofcambodia.org

ប្រាក់ចំណាយគ្រប់យ៉ាងសម្រាប់ក្រុមនេះ នៅលើបន្ទុកនៃថវិកាជាតិ ។

អគ្គាធិការនៃពុទ្ធិកសិក្សា បានធ្វើទស្សនាបរពិនិត្យ - ត្រួតត្រាសាលាពុទ្ធិកបឋមសិក្សាក្នុងព្រះរាជអាណាចក្ររៀងរាល់ឆ្នាំ ។

ការត្រួតត្រានេះ ធ្វើឡើងដើម្បីពិនិត្យមើល :

- ដំណើរនៃការសិក្សានៅសាលានីមួយ ៗ និងការប្រព្រឹត្តទៅនៃសាលាទាំងនោះ,
- ការចំរើននៃថ្នាក់រៀន,
- ការអនុវត្តន៍កម្មវិធីសិក្សា,
- ការប្រើប្រាស់សៀវភៅសិក្សា ។

www.elibraryofcambodia.org

# ពុទ្ធិកបឋមសិក្សា

សាលាពុទ្ធិកបឋមសិក្សា ដែលបានបើកបង្រៀននៅតាមវត្តនានាក្នុងក្រុង និងខេត្តក្រៅ បានកើតឡើងតាំងពីឆ្នាំ ១៩៣៣ ហើយមានការកែប្រែរៀបចំជាក្តីជាបន្តបន្ទាប់មក តាមព្រះរាជក្រឹត្យលេខ ៦០៧ ន.ស. ចុះថ្ងៃទី ១២ ធ្នូ ១៩៤៧ ។ សាលាពុទ្ធិកបឋមសិក្សាសព្វថ្ងៃមាន ៥៩០ សាលា ក្នុងសាលានីមួយៗ មាន ៣ ថ្នាក់ ហើយចំនួនសិស្សទាំងភិក្ខុ-សាមណេរ មាន ១០ ១៥០ រូប ។

ចំនួនអាចារ្យបង្រៀនបានកើនឡើងជាលំដាប់ រហូតមកទល់ឆ្នាំ ១៩៦០-៦១ នេះ មាន ៧៩៩ រូប ដោយមាន ២១២ រូបជាអាចារ្យមានសញ្ញាប័ត្រពុទ្ធិកវិទ្យាល័យ ។

www.elibraryofcambodia.org

## កម្មវិធីសិក្សា

ការសិក្សានៅសាលាពុទ្ធិកបឋមសិក្សា ជាមូលដ្ឋាននៃការសិក្សានៅសាលាពុទ្ធិកមធ្យមសិក្សា ។

មុខវិជ្ជាផ្សេងៗ សម្រាប់សិក្សា ត្រូវបង្រៀនជាភាសាជាតិ ហើយមានដូចតទៅនេះ ៖

- វេយ្យាករណ៍បាលី ឬ ធម្មបទ ....ពី ៧ ដល់ ៨ ម៉ ក្នុង ១ ស័ប
- វិន័យ-ពុទ្ធប្បវត្តិ និងពុទ្ធសាសនា...២ ម៉ោង —
- ភាសាជាតិ : វេយ្យាករណ៍ សរសេរតាមសូត្រ ពាក្យនិងភាសា តែងសេចក្តី អក្សរផ្ចង់ ..........ពី ៤ ដល់ ៦ ម៉ ក្នុង ១ ស័ប
- គណិតសាស្ត្រ.....................ពី ៤ ដល់ ៥ ម៉ —

- ប្រវត្តិសាស្ត្រប្រទេសកម្ពុជា........ ១ ម៉ោង    ក្នុង ១ សប្តាហ៍
- ភូមិសាស្ត្រប្រទេសកម្ពុជា.......... ១ —    —
- វិទ្យាសាស្ត្រ - អនាម័យ............ ពី ២ ដល់ ២ម៉ ៣០ —
- លោកនីតិ ........................ ១ ម៉ោង    —
- វិជ្ជាកសិកម្មយ៉ាងសង្ខេប.......... ៣០ នាទី    —

រយៈកាលនៃការសិក្សានៅសាលាពុទ្ធិកបឋមសិក្សា មានកំណត់ ៣ ឆ្នាំ ក្រោយរយៈកាលនេះ សិស្សអាចចូលប្រឡងយកវិញ្ញាបនប័ត្រពុទ្ធិកបឋមសិក្សាបាន ។

ការឈប់សំរាក និង វិស្សមកាល មានកំណត់ដូចគ្នាទាំងអស់ចំពោះសាលាពុទ្ធិកសិក្សា គឺ :

www.elibraryofcambodia.org

- ថ្ងៃ ៧ និង ៨ កើត,
- ថ្ងៃ ៧ និង ៨ រោច,
- ថ្ងៃកោរ,
- ថ្ងៃពេញបូណ៌មី,
- ថ្ងៃដាច់ខែ,
- វិស្សមកាលតូច : ពីថ្ងៃ ១ រោច ដល់ថ្ងៃ ១៤ រោច ខែអស្សុជ,
- វិស្សមកាលធំ : ពីថ្ងៃ ១ មីនា ដល់ថ្ងៃ ៣០ មេសា ។

## ការសុំបើកសាលាពុទ្ធិកបឋមសិក្សា

ការសុំបើកសាលាពុទ្ធិកបឋមសិក្សា ត្រូវលោកគ្រូចៅអធិការវត្តធ្វើ

ពាក្យសុំ ដោយលោកជាអ្នកទទួលរ៉ាប់រងខាងសម្ភារៈគ្រប់យ៉ាង ដែលជាគ្រឿងចាំបាច់ សម្រាប់បើកសាលានោះ ដូចជា : អាគារ គ្រឿងសង្ហារិម និងប្រដាប់ប្រដាផ្សេង ៗ ទៀត ។

**បុគ្គលិកសិក្សា–** ការតែងតាំងបព្វជិតក្នុងមុខងារ ជាអាចារ្យបង្រៀននៅសាលាពុទ្ធិកបឋមសិក្សា ត្រូវសម្រេចដោយប្រកាសនីយប័ត្រនៃអគ្គាធិការនៃពុទ្ធិកសិក្សា តាមសេចក្តីស្នើសុំពីលោកគ្រូចៅអធិការវត្ត ដោយមានសេចក្តីបញ្ជាក់យល់ព្រមពីរដ្ឋមន្ត្រីក្រសួងធម្មការផង ។ អាចារ្យបង្រៀនទាំងនេះ ត្រូវជ្រើសយកក្នុងចំណោមបព្វជិតមានសញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សា ។ ក្នុងកាលៈទេសៈ ដែលពុំសូវសម្បូណ៌អ្នកមានសញ្ញាប័ត្រនេះ បព្វជិតណាដែលមានវិញ្ញាបនប័ត្រពុទ្ធិកបឋមសិក្សា ក៏អាចតែងតាំងជាអាចារ្យបង្រៀនបានដែរ ។

www.elibraryofcambodia.org

ការរៀបចំទូទៅ និង ការរៀបចំខាងបច្ចេកទេស ដើម្បីញ៉ាំងសាលាពុទ្ធិកបឋមសិក្សាឲ្យមានដំណើរការប្រព្រឹត្តទៅដោយប្រពៃ ឋិតនៅលើគំនិតនៃរដ្ឋមន្ត្រីក្រសួងធម្មការ ។

ការចំរើនក្នុងផ្នែកពុទ្ធិកបឋមសិក្សា ដែលបានសង្កេតឃើញចាប់តាំងពីប្រទេសកម្ពុជាបានឯករាជ្យមក មានលទ្ធផលហួសពីបំណងដែលបានគ្រោងទុកមក ។ ក្នុងមួយឆ្នាំ ៗ មានចំនួនសិស្សជាង២ ០០០រូប បានប្រឡងជាប់វិញ្ញាបនប័ត្រពុទ្ធិកបឋមសិក្សា ។ សិស្សណាដែលមានវិញ្ញាបនប័ត្រនេះហើយ អាចធ្វើពាក្យសុំប្រឡងច្រើងចូលរៀនក្នុងពុទ្ធិកវិទ្យាល័យព្រះ

សុរាម្រឹតបាន ៗ ចាប់តាំងពីឆ្នាំ ១៩៦១ នេះទៅ គ្រឹះស្ថានពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត មានកន្លែង ១៨០ សម្រាប់ទទួលយកសិស្សដែលបានប្រឡងប្រជែងជាប់ឲ្យចូលរៀនតទៅ ៗ

www.elibraryofcambodia.org

# អំពីពុទ្ធិកមធ្យមសិក្សា

«ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត» ជាគ្រឹះស្ថានតែមួយក្នុងព្រះរាជាណាចក្រ សម្រាប់ពុទ្ធិកមធ្យមសិក្សាក្នុងបច្ចុប្បន្ននេះ, កាលដើមមានឈ្មោះថា «សាលាបាលី», បន្ទាប់មកជា «សាលាបាលីជាន់ខ្ពស់» ។ ការរៀបចំកម្មវិធីសិក្សាជាថ្មី ក៏មានដំណាលគ្នានឹងការកែប្រែឈ្មោះនេះដែរ ។

## សាលាបាលី

## ១៩១៤ - ១៩២១

គ.ស. ១៩១៤ បានបង្កើតសាលាបាលីជាបណ្ដោះអាសន្នក្នុងទីព្រះកែវមរកត ក្រុងភ្នំពេញ ក្រោមព្រះបរមរាជូបត្ថម្ភនៃព្រះករុណា ជាអម្ចាស់ជីវិត ព្រះបាទសម្តេចព្រះ **ស៊ីសុវត្ថិ** (ព្រះរាជប្រកាសលេខ ៨៥ ចុះថ្ងៃទី ២៤ វិច្ឆិកា ១៩១៤) ។ នៅខែវិច្ឆិកា ឆ្នាំ ១៩១៤ មានបើកសម័យប្រឡងប្រជែងរើសសាស្ត្រាចារ្យ ៥ រូប ។ ការជ្រើសរើសសមណសិស្សជាដំបូងបានធ្វើនៅខែកុម្ភៈ ឆ្នាំ ១៩១៥ ដោយវិធីប្រឡងប្រជែង ។

www.elibraryofcambodia.org

សិស្សចំនួន ៦០ រូបបានចូលសិក្សា :

នៅថ្នាក់ឆ្នាំទី ១ : ២០ រូប

-ដ- ២ : ២០ រូប

-ដ- ៣ : ២០ រូប

រយៈកាលនៃការសិក្សា បានកំណត់ត្រឹម ៣ ឆ្នាំ ។

កម្មវិធីសិក្សា មានត្រឹមតែការសូត្ររៀនភាសាបាលី មូលវេយ្យាករណ៍ ប្រែគម្ពីរធម្មបទដ្ឋកថា មង្គលត្ថទីបនី បឋមសមន្តប្បាសាទិកា

វិសុទ្ធិមគ្គ និង អភិធម្មត្ថសង្គហៈ ។

នៅ គ. ស. ១៩១៧ មានបើកសម័យប្រឡងចេញយក **សញ្ញាប័ត្រ សាលាបាលី** ជាលើកដំបូង, សមណសិស្ស ១៦ រូប បានប្រឡងជាប់ មានឋានន្តរៈជាទី «មហា» ។

របៀតដល់ឆ្នាំសិក្សា ១៩២១ :

សាលាបាលីបានជ្រើសរើសសមណសិស្សឲ្យចូលរៀន តាមវិធីប្រឡងប្រជែង ចំនួន ២០ រូប រៀងរាល់ឆ្នាំ សំរាប់ថ្នាក់ឆ្នាំទី ១ ។

– សមណសិស្ស ៤៥ រូប បានប្រឡងជាប់សញ្ញាប័ត្រសាលាបាលី តាមកម្មវិធីសិក្សានេះ ។

ដោយហេតុកម្មវិធីសិក្សានេះ មិនអាចឲ្យសមណសិស្សមានទស្សនៈទូលាយ ដើម្បីនឹងយល់នូវតម្លៃនៃព្រះពុទ្ធសាសនាបាន ទើបមានការរៀបចំជាដំបូងនូវរបៀបសិក្សា ហើយកែប្រែឈ្មោះសាលាជា «**សាលាបាលីជាន់ខ្ពស់**» វិញ ។

www.elibraryofcambodia.org

## សាលាបាលីជាន់ខ្ពស់

## ១៩២២ - ១៩៥៥

### អំពីទីស្ថាបនា :

– គ. ស. ១៩២២ រាជការបានកសាងអាគារមួយនៅជ្រុងផ្សារស្នួល សម្រាប់សាលាបាលី ហើយបានរើចេញពីទីព្រះវិហារព្រះកែវមរកតមកនៅទីថ្មីនេះ ដែលសព្វថ្ងៃបានរៀបចំជាមន្ទីរពុទ្ធសាសនបណ្ឌិត្យ និងក្រសួងធម្មការ ។

សាលាបាលីក៏បានប្រែឈ្មោះថា **«សាលាបាលីជាន់ខ្ពស់»** ដោយមាន ៤ ថ្នាក់ តាមកំណត់រយៈកាលថ្មីនៃការសិក្សា (ព្រះរាជប្រកាសលេខ ៩៧ ន.ស. ចុះថ្ងៃទី ១៣ មេសា ១៩២២) ។

– គ.ស. ១៩២៥ រាជការបានបង្កើត **«ព្រះរាជបណ្ណាល័យកម្ពុជា»** មិនទាន់មានទីសំណាក់ការ រាជការក៏បានសុំយកទីសាលាបាលីជាន់ខ្ពស់ឲ្យទៅជា **«ព្រះរាជបណ្ណាល័យកម្ពុជា»** ។ សាលាបាលីជាន់ខ្ពស់ ត្រូវលើកត្រឡប់ទៅឯទីព្រះវិហារព្រះកែវមរកតវិញម្តងទៀត ។ ដល់ គ.ស. ១៩២៦ រាជការបានយកសាលាបារាំងខ្មែរ **«ផ្សារស្នួន»** បង្វែរឲ្យមកជាអាគារសម្រាប់សាលាបាលីជាន់ខ្ពស់ជាប់រហូតដល់សព្វថ្ងៃនេះ (សាលាផ្សារស្នួនដែលកើតក្នុង គ.ស. ១៩១៦ ត្រូវលើកយកទៅបញ្ចូលជាមួយនឹងសាលាឯទៀតវិញ ក្នុង គ.ស. ១៩២៧) ។

www.elibraryofcambodia.org

## អំពីការត្រួតត្រា :

សាលាបាលីជាន់ខ្ពស់ស្ថិតនៅក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃព្រះមហាក្សត្រខ្មែរ ។

កាលនៅក្នុងអាណាព្យាបាលបារាំង សាលាបាលីជាន់ខ្ពស់ឡើងផ្ទាល់ទៅក្រសួងសិក្សាធិការជាតិពេលដំបូង ទៅក្រសួងធម្មការពេលបន្ទាប់ ក្រោមការត្រួតពិនិត្យនៃរេស៊ីដង់ស៊ុប៉េរីយើរនៅប្រទេសកម្ពុជា ។

បុគ្គលិក មាន : ចាងហ្វាង ១ រូប<br>
ចាងហ្វាងរង ១ រូប<br>
និងសាស្ត្រាចារ្យ ។

បានតាំងជាចាងហ្វាងនៃសាលាបាលីជាន់ខ្ពស់តាមលំដាប់ ៖

– ព្រះមហាវិមលធម្ម « **ថោង** » : ១៩១៤ - ១៩២៧

– ព្រះសិរីសម្មតិវង្ស « **ឯម** » : ១៩២៧ - ១៩៤២

– ព្រះពុទ្ធឃោសាចារ្យ «**ជួន-ណាត**» : ១៩៤២ - ១៩៤៨

"សម្តេចព្រះសង្ឃនាយកគណៈមហានិកាយសព្វថ្ងៃ"

ព្រះពោធិវង្ស «**ហួត-តាត**» : តាំងពីខែ សីហា ១៩៤៨ រហូតដល់បច្ចុប្បន្ននេះ ។

ចាងហ្វាងរង :

– ព្រះមហាព្រហ្មមុនី «**ទេព-អ៊ូ**» ពីឆ្នាំ ១៩៤២ រហូតដល់សព្វថ្ងៃនេះ ។

## កម្មវិធីសិក្សា :

www.elibraryofcambodia.org

– រយៈកាលនៃការសិក្សា បានកំណត់ត្រឹម ៤ ឆ្នាំ ។

– កម្មវិធីសិក្សា មានការកែប្រែច្រើនលើក ដោយសរុបវិជ្ជាដែលត្រូវបង្រៀនក្នុងសាលាបាលីជាន់ខ្ពស់ស្របទៅតាមវត្ថុបំណងនៃការអប់រំក្នុងអាគារពុទ្ធិកសិក្សានេះ ដែលប្រាថ្នាឲ្យភិក្ខុសាមណេរយល់នូវអត្ថរសនៃព្រះពុទ្ធសាសនា ដោយបន្ថែមវិជ្ជាផ្សេង ៗ ដទៃទៀតខាងផ្លូវលោកលើការសិក្សាភាសាបាលី និងសំស្រ្កឹត ។

វិជ្ជាដែលបង្រៀន មានដូចតទៅនេះ :

១– មូលភាសា : បាលី សំស្រ្កឹត

២– អក្សរសាស្រ្តខ្មែរក្នុងសាសននិយម និងពាហិរនិយម

៣– ប្រវត្តិនយោបាយ សាសនា និងសិល្បៈ នៅប្រទេសខ្មែរ

៤– ប្រវត្តិទូទៅនៃព្រះពុទ្ធសាសនា

៥– គោលនិយមនៃព្រះពុទ្ធសាសនា

៦– ភូមិសាស្ត្រប្រទេសឥណ្ឌូចិន និងប្រទេសជិតខាង ជាពិសេសប្រទេសកាន់ព្រះពុទ្ធសាសនា, ភូមិសាស្ត្រសាកលដោយសង្ខេប, ពូជពង្សមនុស្សនៅចុងបូព៌ាប្រទេស, សាសនា,ការវិវឌ្ឍន៍

៧– ភាសាបាលី : វាក្យសព្ទ, ការអាន និងការពន្យល់វេយ្យាករណ៍ វាក្យបរិវត្តន៍

៨– នព្វន្ត

៩– ប្រវត្តិសាសនាសាកលលោក

១០– ប្រវត្តិសាស្ត្រនយោបាយ និងសេដ្ឋកិច្ចសម័យបច្ចុប្បន្ននៃសាកលលោក

www.elibraryofcambodia.org

១១– វិទ្យាសាស្ត្រធម្មជាតិ និងអនាម័យ ផ្ដើមរៀនពីឆ្នាំ ១៩៥២ ។

## អំពីការប្រឡង :

មានការកែប្រែបទបញ្ញត្តិច្រើនលើក ដោយសរុបចំនួនមុខវិញ្ញាសា មិនលើសខ្វះពីគ្នាប៉ុន្មានក្នុងការប្រឡង មានវិញ្ញាសាសរសេរនិងវិញ្ញាសាសួរផ្ទាល់មាត់ ។

## ក- ការប្រឡងប្រជែងចូលរៀន:

### វិញ្ញាសាសរសេរ :

១ – អនុវាក្យខ្មែរ

២– ប្រែបាលីជាខ្មែរ ស្រង់ពីគម្ពីរអដ្ឋកថាធម្មបទ

៣– អធិប្បាយធម្មបទគាថា

៤– តែងរឿងនិទាន ។

**វិញ្ញាសាសួរផ្ទាល់មាត់** មានត្រឹមតែសម័យប្រឡងចូល ឆ្នាំ ១៩៥២ ៖

១— មូលវេយ្យាករណ៍

២— ពុទ្ធប្រវត្តិ

៣— រឿងពុទ្ធសាសនា

៤— វិន័យ ។

ការប្រឡងប្រជែងជ្រើសរើសសមណសិស្សឲ្យចូលរៀននៅសាលាបាលីជាន់ខ្ពស់មានបើករៀងរាល់ឆ្នាំ យកតាមចំនួនកន្លែងដែលបានកំរិតទុកជាមុន ដូចមានជាភាគផងតទៅនេះ ៖

www.elibraryofcambodia.org

| | | | | | |
|---|---|---|---|---|---|
| ពី គ. ស. | ១៩២២ | ដល់ | ១៩២៧ | : | ២៥ កន្លែងក្នុង ១ ឆ្នាំ |
| - | ១៩២៨ | - | ១៩៣២ | : | ៣០ - |
| - | ១៩៣៣ | - | ១៩៤៣ | : | ៣៥ - |
| - | ១៩៤៤ | - | ១៩៤៦ | : | ៤០ - |
| - | ១៩៤៧ | - | ១៩៥៤ | : | ១០០ - |
| - | ១៩៥៥ | | | : | ១៥០ - |

ចំនួនភិក្ខុសមណៈសុំប្រឡងចូលមានពី ១០០ រូបដល់ ៦០០ រូប ពី គ. ស. ១៩២២ ដល់ គ. ស. ១៩៣២ ។ តាំងពីបានបង្កើតសាលាពុទ្ធិកបឋមសិក្សា គ. ស. ១៩៣៣ មក ភិក្ខុសមណៈមានចំនួនកាន់តែកើនឡើង

តាំងពីជាង ២០០ រូប ដល់ជិត ២.០០០ រូបក្នុងមួយឆ្នាំៗ ជាហេតុនាំឲ្យបង្កើនបន្ទប់ថ្នាក់ឆ្នាំទី ១ នេះជាពីរបន្ទប់ ពី គ.ស. ១៩៤៧ ដល់ ១៩៥៤, ជា ៣ បន្ទប់ ពី គ.ស. ១៩៥៥ - ១៩៦០ ។

ក្រៅអំពីសមណសិស្សដែលជ្រើសរើសដោយការប្រឡងនេះ សាលាបាលីជាន់ខ្ពស់បានទទួលព្រះសង្ឃពីប្រទេសក្រៅ គឺកម្ពុជាក្រោម លាវ ឲ្យចូលមកសិក្សាចំនួន ២០ អង្គរៀងរាល់ឆ្នាំ តាំងពីឆ្នាំ ១៩៤២ ដរាបមក ជាសិស្សស្ដាប់ស្វែរ (ពី គ.ស. ១៩៤០ ដល់ ១៩៥១) រួចជាសិស្សពេញទី (ពីឆ្នាំ ១៩៥២ រៀងមក); សមណសិស្សពីប្រទេសលាវ មិនបានសុំចូលសិក្សាតាំងពី គ.ស. ១៩៦០ ទៀតឡើយ ។

## ខ- ការប្រឡងចេញ :

www.elibraryofcambodia.org

លុះចប់ការសិក្សាគ្រប់ ៤ ឆ្នាំ សមណសិស្សត្រូវប្រឡងចេញយកសញ្ញាប័ត្រ ហៅថា : **សញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ ។**

មុខវិញ្ញាសាប្រឡងចេញ មានដូចតទៅ ៖

### វិញ្ញាសាសរសេរ

១- ប្រែបាលីរៀងសេចក្ដីជាខ្មែរ

២- ប្រែសំស្រ្កឹត អក្សរទេវនាគរីជាខ្មែរ

៣- ប្រែពីខ្មែរទៅជាភាសាបារាំង

៤- អធិប្បាយសេចក្ដីក្នុងព្រះវិន័យ ឬ ព្រះអភិធម្ម

៥- ប្រែពីខ្មែរទៅជាភាសាបាលី

៦- តែងសេចក្ដីជាភាសាបាលី ។

## វិញ្ញាសាសួរ :

មានត្រឹមសម័យប្រឡង គ. ស. ១៩៥៣

១– ប្រែពន្យល់សំស្រ្កឹតទេវនាគរី សរសេរជាអក្សរខ្មែរអក្សរឡាតាំង…

២– សំនួរអំពីសាសនា - ការរចនាបុណក្នុងកម្ពុជរដ្ឋ

៣— ពុទ្ធប្បញ្ញត្តិ ឲ្យសូត្របាលីភិក្ខុបាតិមោក្ខ - សួរសេចក្តី

៤– ប្រវត្តិសាសនានានា

៥– អក្សរសាស្ត្រខ្មែរ

៦— សំនួរអំពីភូមិសាស្ត្រ ទ្វីបអាស៊ីខាងកើត និងប្រជាយត់ណ្ឌូចិន…

៧— សន្ទនាជាបារាំង

៨— សំនួរខាងលេខនព្វន្ត

www.elibraryofcambodia.org

៩– សន្ទនាជាភាសាបាល

១០– សំនួរខាងពង្សាវតារផ្លូវរាជការ នយោបាយ និងការបំរើនក្នុង…
សម័យបច្ចុប្បន្ន

១១– សំនួរអំពីចរិយាសាស្ត្រ និងលោកនីតិ ។

បានលុបវិញ្ញាសាសួរផ្ទាល់មាត់ក្នុងការប្រឡង ហើយបានបន្ថែមមុខ… វិញ្ញាសាសរសេរ ដោយអនុវត្តតាមព្រះរាជក្រិត្យលេខ ១០៣ ន.ស. ចុះថ្ងៃ… ទី ១៧ មីនា ១៩៥២ : –ប្រឡងចូលពី ១៩៥៣ ដល់ ១៩៥៥, វិញ្ញាសា… សរសេរទាំងអស់ ៨ មុខ គឺបន្ថែមការគិតចតុព្វិធលេខ តែងសេចក្តីខ្មែរ;

–ប្រឡងចេញពី ១៩៥៤ ដល់ ១៩៥៨ : វិញ្ញាសាទាំងអស់ ១៣ មុខ… គឺមានបន្ថែមតែងសេចក្តីជាភាសាបារាំង ចំណោទក្នុងចតុព្វិធលេខ វិទ្យា-

សាស្ត្រធម្មជាតិ និងអនាម័យ ។

មកត្រឹម គ.ស. ១៩៥៨ សមណសិស្សទាំងអស់ ១.៤២៥ រូប បាន ប្រឡងជាប់សញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ តាមកម្មវិធីសិក្សានេះ មានឋានន្តរៈជា «មហាឧត្តមវិជ្ជា» ។

សមណសិស្សស្ដាប់ស្ទើរនៃចំនួន ៥៤ រូបទៀត បានទទួលសិក្សាប័ត្របញ្ជាក់ការសិក្សាគ្រប់រយៈ ៤ ឆ្នាំ ។

ការសិក្សានៅសាលាបាលីជាន់ខ្ពស់ រីកចំរើនកើនជាងសម័យមុនច្រើន ដោយការប្រាស្រ័យទាក់ទងជាមួយនឹងពុទ្ធសាសនបណ្ឌិត្យផង ។

សៀវភៅពប់រយមុខ គាំងពីវចនានុក្រមខ្មែរ ព្រះត្រៃបិដក សៀវភៅខាងព្រះពុទ្ធសាសនា ខាងអក្សរសាស្ត្រ ។ល។ បានផ្សាយចេញដោយសារតែមានការសិក្សាក្នុងសាលាបាលីជាន់ខ្ពស់នេះ ជាហេតុនាំឲ្យមានកិត្តិស័ព្ទល្បីខ្ទរទៅដល់ប្រទេសនានាក្នុងរឿងព្រះពុទ្ធសាសនានៅប្រទេសខ្មែរ ។

លុះប្រទេសខ្មែរបានឋានៈជាប្រទេសឯករាជ្យហើយ គណកម្មការមួយបានតាំងឡើង ដើម្បីពិនិត្យនឹងរៀបចំកម្មវិធីពុទ្ធិកមធ្យមសិក្សា ។

សាលាបាលីជាន់ខ្ពស់ដែលបានប្រែឈ្មោះថា « ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត» តាមព្រះរាជក្រឹត្យលេខ ៣៨៨ ន.ស. ចុះថ្ងៃទី ៤ កក្កដា គ.ស. ១៩៥៥ មានរបៀបរៀបចំថ្មី នឹងកម្មវិធីសិក្សាថ្មី រហូតដល់សព្វថ្ងៃ ។

www.elibraryofcambodia.org

# ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត

ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ស្ថិតនៅក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃព្រះមហាក្សត្រ ។

ការរើរៀបចំរបៀបសិក្សាជាថ្មី តាមព្រះរាជក្រឹត្យលេខ ២៦៥ ន.ស. ចុះថ្ងៃទី ១៨ ឧសភា ឆ្នាំ ១៩៥៥ មានគោលបំណងដើម្បី :

— ញ៉ាំងការប្រតិបត្តិតាមព្រះពុទ្ធសាសនា ឲ្យមានថាមភាពខ្លាំងក្លាឡើង

— ជំរុញចិត្តស្រឡាញ់វប្បធម៌និងអារ្យធម៌ជាតិឲ្យមានសន្ទុះឡើង

— បណ្ដុះមនោសញ្ចេតនានៃមនុស្សជាតិ ដោយឲ្យសមណសិស្សស្គាល់នូវវប្បធម៌-អារ្យធម៌របស់ប្រទេសនានា

— អប់រំប្រាជ្ញានិងសន្តានចិត្តឲ្យរីកសាយចំរើនឡើងដោយសុខដុម

www.elibraryofcambodia.org

— ហ្វឹកហ្វឺនសមណសិស្សឲ្យមានសមត្ថភាពអាចនឹងបន្តការសិក្សានៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជបាន ។

## ការត្រួតត្រា – បុគ្គលិក

— គ្រឹះស្ថានស្ថិតនៅក្នុងការត្រួតត្រាផ្ទាល់នៃក្រសួងធម្មការ ។ ចំណាយគ្រប់យ៉ាងដើម្បីញ៉ាំងអាគារសិក្សានេះឲ្យប្រព្រឹត្តទៅនៅក្នុងបន្ទុកនៃថវិកាជាតិ ។ មានក្រុមប្រឹក្សាភិបាលមួយ សម្រាប់ពិនិត្យដំណើរការប្រព្រឹត្តទៅនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត មានសមាសភាពដូចតទៅនេះ ៖

- រដ្ឋមន្ត្រីក្រសួងធម្មការ ឬអ្នកតំណាង ....... ជាប្រធាន
- តំណាងសង្ឃនាយកគណៈមហានិកាយ ...... ជាសមាជិក

- តំណាងសង្ឃនាយកគណៈធម្មយុត្តិ ........ ជាសមាជិក
- ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ........ —
- សាស្ត្រាចារ្យ ៣ រូប ................. —
- សាស្ត្រាចារ្យចាត់អំពីរដ្ឋមន្ត្រីក្រសួងសិក្សាធិការជាតិ ១ រូប —

ក្រុមប្រឹក្សាភិបាលត្រូវរួមប្រជុំមួយដងក្នុងមួយឆ្នាំ ក្រោយពេលដែលប្រឡងចេញរួច ដើម្បីនឹងពិនិត្យអំពីលទ្ធផលនៃការសិក្សាក្នុងឆ្នាំដែលទើបកន្លងផុតទៅ ហើយធ្វើសេចក្តីស្នើសុំឲ្យពិនិត្យជាថ្មីនូវកម្មវិធីសិក្សាវិធានការ និងសេចក្តីណែនាំផ្សេង ៗ ដែលយល់ឃើញថាគួរលើកយកមកពិនិត្យ ដើម្បីជាមាគ៌ាធ្វើឲ្យគ្រឹះស្ថាន មានដំណើររៀបរយអាចសម្រេចលទ្ធផលបានល្អប្រពៃឡើង ៗ

www.elibraryofcambodia.org

ឯកិច្ចចាត់ការក្នុងគ្រឹះស្ថានសិក្សាជាភារៈលើ :

- ចាងហ្វាង ១ រូប : ព្រះពោធិវ័ង្ស **ហួត-តាត**
- ចាងហ្វាងរង ១ រូប : ព្រះមហាព្រហ្មមុនី **ទេព-អ៊ួ**

ដោយមានចាងហ្វាងការសិក្សា ១ រូប និងអនុរក្សជួយបំពេញមុខងារផង ៗ

បុគ្គលិកសាស្ត្រាចារ្យមាន :

- មួយផ្នែកជាសាស្ត្រាចារ្យបព្វជិតចំនួន ៨ អង្គ និងជាបុគ្គលិកក្នុងក្របខ័ណ្ឌសាស្ត្រាចារ្យគ្រហស្ថ ចំនួន ៧ រូប បង្រៀនបាលី សំស្ក្រឹត - ខ្មែរ និងអង់គ្លេស
- មួយផ្នែកទៀត ជាសាស្ត្រាចារ្យដែលក្រសួងសិក្សាធិការជាតិបានផ្តល់

ឲ្យមកមានចំនួន ៤ រូប បង្រៀនភាសា បារាំង គណិតសាស្ត្រ ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ។

ក្នុងបច្ចុប្បន្ននេះ ដោយនៅមានការខ្វះបុគ្គលិក ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ត្រូវការសាស្ត្រាចារ្យមធ្យមសិក្សាមកបង្រៀននូវវិជ្ជាគណិតសាស្ត្រ វិទ្យាសាស្ត្ររូបនិយមនឹង គីមី ថ្នាក់លើទាំងឡាយ ជារង្វាន់ម៉ោង ។

ក្នុងក្របខណ្ឌជាកិច្ចប្រគាផ្នែកវប្បធម៌ អង្គការជាតិបរទេសបានជួយផ្ដល់មកឲ្យពុទ្ធិកវិទ្យាល័យនូវសាស្ត្រាចារ្យខ្លះសម្រាប់បង្រៀន :

— ភាសាអង់គ្លេស ១ រូប ពីមូលនិធិអាស៊ី

— ភាសាបារាំង ២ រូប ពីបេសកកម្មវប្បធម៌បារាំងសេស

— ភាសាសំស្ក្រឹត ១ រូប ពីស្ថានទូតឥណ្ឌា ។

www.elibraryofcambodia.org

## ការប្រឡងប្រជែងចូលរៀន

រាល់ឆ្នាំ ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត បើកឲ្យសមណសិស្សដែលមានវិញ្ញាបនប័ត្រពុទ្ធិកបឋមសិក្សា ប្រឡងប្រជែងចូលរៀន ។

ការប្រឡងប្រជែងមានតែមុខវិញ្ញាសាសរសេរដូចតទៅនេះ :

១— ប្រែបាលីជាខ្មែរ មានសំនួរ

២— សរសេរតាមសូត្រខ្មែរ មាន ឬ ឥតសំនួរ ឬ តែងសេចក្ដីខ្មែរ

៣— ប្រស្នាវិន័យ

៤— ចំណោទក្នុងចតុព្វិធលេខ ។

# កម្មវិធីសិក្សា

កម្មវិធីសិក្សាបានរៀបចំ ស្របទៅតាមគោលបំណងនៃការអប់រំក្នុងគ្រឹះស្ថាន ហើយអាស្រ័យតាមគោលការណ៍ដូចតទៅនេះ :

— រក្សាដំណែលកម្មវិធីសិក្សាទាំងស្រុង ក្នុងការបង្រៀនបាលី និងសំស្ក្រឹត ដែលជាមូលដ្ឋានសំខាន់មួយ ដើម្បីស្គាល់នូវភាសានិងវប្បធម៌ជាតិឲ្យជ្រៅជ្រះ

— ដំឡើងកម្មវិធីឲ្យមានលំនាំជាមធ្យមសិក្សា ដោយបញ្ចូលមុខវិជ្ជាថ្មីខ្លះ មានពីជគណិត រេខាគណិត វិទ្យាសាស្ត្ររូបនិយម គីមីផង ដោយកែប្រែកម្មវិធីខាងប្រវត្តិសាស្ត្រ ភូមិសាស្ត្រ វិទ្យាសាស្ត្រធម្មជាតិ និងអនាម័យផង

www.elibraryofcambodia.org

— ប្រើភាសាជាតិជាយានភាសា ក្នុងការបង្រៀនមុខវិជ្ជាទាំងអស់ លើកលែងតែក្នុងមុខវិជ្ជាបាលីនិងអង់គ្លេសចេញ ។

## តារាងមុខវិជ្ជាបង្រៀនក្នុងថ្នាក់នីមួយ ៗ នឹងចំនួនម៉ោងក្នុង ១ អាទិត្យ :

| មុខវិជ្ជា | | ចំនួនម៉ោងក្នុងមួយអាទិត្យ | | | |
|---|---|---|---|---|---|
| | | ថ្នាក់ឆ្នាំទី ១ | ថ្នាក់ឆ្នាំទី ២ | ថ្នាក់ឆ្នាំទី ៣ | ថ្នាក់ឆ្នាំទី ៤ |
| មូលភាសា | បាលី | ៨ ម៉ | ៦ ម៉ | ៥ ម៉ | ៤ ម៉ |
| | សំស្ក្រឹត | | ៣ ម៉ | ៣ ម៉ | ៣ ម៉ |
| ភាសាជាតិ | | ២ ម៉ | ២ ម៉ | ២ ម៉ | ២ ម៉ |

| | | | | | |
|---|---|---|---|---|---|
| ជីវភាសា | អង់គ្លេស | ៥ម៉" | ៥ម៉" | ៥ម៉" | ៤ម៉" |
| | បារាំង | ៤ម៉" | ៤ម៉" | ៤ម៉" | ៤ម៉" |
| ប្រវត្តិសាស្ត្រ | | ២ម៉" | ១ម៉" | ១ម៉" | ២ម៉" |
| ភូមិសាស្ត្រ | | ១ម៉" | ១ម៉" | ១ម៉" | ១ម៉" |
| គណិតសាស្ត្រ | | ៥ម៉" | ៤ម៉" | ៤ម៉" | ៤ម៉" |
| វិទ្យាសាស្ត្រ | ធម្មជាតិ | ២ម៉" | ១ម៉" | ១ម៉" | ១ម៉" |
| | រូបនិយម | | ២ម៉" | ១ម៉" | ១ម៉" |
| | គីមី | | ១ម៉" | ១ម៉" | ១ម៉" |
| លោកនីតិ | | ១ម៉" | | | ១ម៉" |
| វិជ្ជាទូទៅ : ប្រវត្តិ. | | | | ១ម៉" | |
| សាសនាអារ្យធម៌ខ្មែរ | | | | | ១ម៉" |
| បូករួម...... | | ៣០ម៉" | ៣០ម៉" | ៣០ម៉" | ៣០ម៉" |

www.elibraryofcambodia.org

## ការប្រឡងចេញ

លុះចប់ការសិក្សាគ្រប់រយៈ ៤ ឆ្នាំហើយ សមណសិស្សត្រូវប្រឡង យកសញ្ញាប័ត្រហៅថា «**សញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សា**» ។

ការប្រឡងនេះមានតែវិញ្ញាសាសរសេរដូចតទៅនេះ :

១— ប្រែបាលីជាខ្មែរ ឬ ផ្ទុយ រយៈពេល ...... ២ម៉ោង

២— ប្រែសំស្ក្រឹតជាខ្មែរ — ...... ២ម៉ោង

៣— ប្រែបារាំងឬ អង់គ្លេសជាខ្មែរ ឬផ្ទុយ ...... ២ម៉ោង

៤— អធិប្បាយព្រះវិន័យ ឬ ព្រះអភិធម្ម ...... ៣ម៉ោង

៥— ប្រវត្តិសាស្ត្រ - ភូមិសាស្ត្រ ...... ២ ម៉ោង

៦— គណិតសាស្ត្រ ...... ២ ម៉ោង

៧— { វិ. ធម្មជាតិ - អនាម័យ
រូបវិទ្យា - គីមី ...... ២ ម៉ោង ។

ព្រះរាជក្រឹត្យ លេខ ២០៦ ន.ស. ចុះថ្ងៃទី ២៤ ឧសភា ឆ្នាំ ១៩៦០ បាន អនុញ្ញាតបើកឲ្យមានសម័យប្រឡងយកសញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សាពីរលើក ក្នុងមួយឆ្នាំ ។

## ស្ថិតិ

ចំនួនសិស្ស និងបេក្ខជនការប្រឡងចូល និងចេញ តាំងពីមានការបើរៀបចំពុទ្ធិកមធ្យមសិក្សាមក ៖

| ឆ្នាំសិក្សា | ចំនួនសិស្សថ្មី | ចំនួនបន្ទប់រៀន | សរុប ចំនួនសិស្ស | សញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សា | |
|---|---|---|---|---|---|
| | | | | ចំនួនបេក្ខសមណៈ | ជាប់ |
| ១៩៥៥ - ៥៦ | ១៥៧ | ៩ | ៥៥៧ | | |
| ១៩៥៦ - ៥៧ | ១៥០ | ១០ | ៦១០ | | |
| ១៩៥៧ - ៥៨ | ១៦៦ | ១១ | ៦៥០ | | |
| ១៩៥៨ - ៥៩ | ១៧៤ | ១២ | ៦៦៦ | ១៤៧ | ៩៧ |
| ១៩៥៩ - ៦០ | ១៧០ | ១២ | ៧០៥ | លើកទី ១ - ១៩៦ | ១១២ |
| | | | | – ទី ២ - ៧៩ | ១២ |
| ១៩៦០ - ៦១ | ១៥៦ | ១២ | ៦៥៦ | លើកទី ១ - ២១៨ | ១៦០ |
| | | | | – ទី ២ - ៥៣ | ២ |
| ១៩៦១ - ៦២ | ១៨៤ | ១៣ | ៦៨០ | | |

www.elibraryofcambodia.org

# សេចក្តីសន្និដ្ឋាន

ការរៀបចំពុទ្ធិកសិក្សាឲ្យមានជាភូមិសិក្សាបី នឹងកម្មវិធីប្រសើរបែបនេះ
នាំឲ្យមានសេចក្តីចំរើនឥតប្រមាណ ។ ការណែនាំសមណសិស្សនោ
ពុទ្ធិកសិក្សាឲ្យស្គាល់នូវវិជ្ជាទាំងឡាយដែលមានក្នុងសម័យបច្ចុប្បន្ន នឹងឲ្យ
ស្គាល់នូវវប្បធម៌-អារ្យធម៌នៃប្រទេសនានា ទាំងនេះជាកំឡាំងមួយអាចបន្ថែម
ទៅលើលក្ខណៈវិទ្យាសាស្ត្រនឹងលក្ខណៈមនុស្សជាតិដែលមានជាលំអានក្នុង
ព្រះពុទ្ធសាសនាស្រាប់ ។

សមណសិស្សដែលប្រឡងជាប់សញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សា ហើយ
ដែលមិនត្រូវបានចូលបន្តការសិក្សានៅពុទ្ធិកមហាវិទ្យាល័យទៀតទេ សម
ណសិស្សនោះតែងត្រឡប់ទៅកាន់វត្តកំណើតវិញ ជួយបង្រៀនក្នុងសាលា
ពុទ្ធិកបឋមសិក www.elibraryofcambodia.org តិច ។ សមណបារ្យនោ
ដោយបានសិក្សាអស់ថិរៈវេលា ៤ ឆ្នាំ នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត មាន
ចំណេះវិជ្ជានឹងការអប់រំគ្រប់គ្រាន់ល្មមនឹងបំពេញករណីយកិច្ចក្នុងឋានៈជាអ្ន
ផ្សាយព្រះពុទ្ធសាសនា ព្រមទាំងជួយណែនាំឧបាសក-ឧបាសិកា ដែល
តែងតែចូលមកពិគ្រោះសាកសួរសព្វកិច្ចការជាធម្មតា ។

ព្រះពុទ្ធសាសនា ជាសាសនាតែងដឹកនាំមនុស្សជាតិឲ្យមានវិរិយភា
នឹងមេត្តាចិត្ត ដើម្បីកែសភាពដើមរបស់មនុស្សឲ្យប្រែក្លាយទៅជាសភាព
ដ៏សមរម្យល្អក្នុងសង្គមមនុស្ស ។ ព្រះពុទ្ធសាសនាគឺពុទ្ធោវាទនេះហើយ
ដែលបានជ្រួតជ្រាបក្នុងសន្តានចិត្តនៃពុទ្ធបរិស័ទទាំងឡាយ ទាំងព្រះសង្
ទាំងគ្រហស្ថ ដរាបដល់បានធ្វើពលិកម្មគ្រប់យ៉ាង ដើម្បីរក្សាកេរ្តិ៍ដំណែ
វប្បធម៌ជាតិ នឹងសន្តិភាពឲ្យបានគង់វង់ឋិតថេរជាស្ថាពរតរៀងទៅ ។

www.elibraryofcambodia.org

# Aperçu sur

# L'ENSEIGNEMENT DU BOUDDHISME AU CAMBODGE

(Edité par le Service d'inspection et de contrôle des Etablissements d'enseignement du Bouddhisme)

www.elibraryofcambodia.org

**EN SOUVENIR**

de la CONFERENCE GENERALE de L'ASSOCIATION MONDIALE du BOUDDHISME

organisée à PHNOM-PENH — Cambodge — du 12 au 22 Novembre 1961

www.elibraryofcambodia.org

# L'ENSEIGNEMENT DU BOUDDHISME AU CAMBODGE

L'organisation de l'enseignement du Bouddhisme au Cambodge, tout en permettant aux moines d'acquérir des connaissances de plus en plus approfondies, a contribué à créer une unité de vue quant à l'interprétation de la Doctrine et à l'application des préceptes moraux édictés par le Vénéré Maître. Si cette identité de formation des religieux a pu s'étendre à travers le Royaume, cela est dû à l'action Royale religieuse poursuivie notamment depuis le règne de Sa Majesté ANG DUONG, poète national, adepte fervent qui organisait l'enseignement du Tripitaka dans plusieurs monastères qu'Elle fit construire à Oudong, donnait Elle-même des cours de Pâli pendant la période de "retraite des moines".

L'enseignement était, jusqu'au début du 20è siècle, resté oral. De temps à autre se déroulait, sous la Haute Tutelle de Sa Majesté le Roi, sur la proposition de l'Ordre des moines, un examen qui ne comportait que des épreuves orales de traduction de Pâli en Khmer. Le titre de " Moha bey prâyôk " était conféré à tout candidat qui pouvait traduire devant un jury d'examen, trois fragments de texte pâli tirés du Dhammapada, une heure étant accordée pour la traduction de chaque fragment d'une longueur de deux feuilles de latanier ; les titulaires pouvaient se présenter ensuite à l'examen pour l'obtention du titre suivant de " Moha buon prâyôk " jusqu'au titre de " Moha pram buon prâyôk ".

www.elibraryofcambodia.org

Sous le Protectorat français (établi sur le Cambodge par le Traité du 11 Août 1863), parallèlement à la mise en place des premiers Etablissements d'enseignement franco-khmer, l'Enseignement du Bouddhisme fut l'objet d'une organisation officielle; le Cambodge vit naître, en 1914, à Phnom-Penh "l'Ecole de Pâli", dénommée par la suite "Ecole Supérieure de Pâli", et en 1933, dans toute l'étendue du Royaume des " Ecoles Elémentaires de Pâli ". Parmi les moines diplômés ou certifiés des Ecoles de Pâli, les uns enseignent dans les Ecoles Elémentaires de Pâli, les autres assurent l'enseignement traditionnel dans les "Ecoles de pagodes" réunissant dans ces dernières années un effectif global de 81.000 enfants.

Depuis l'accession du Cambodge à l'Indépendance (1953), l'enseignement du Bouddhisme a subi une réforme importante suivant les Hautes Instructions de Sa Majesté NORODOM SIHANOUK VARMAN : - l'enseignement comporte trois cycles, cycle primaire, cycle secondaire et cycle supérieur du Bouddhisme,

- l'Université Preah Sihanouk Raj a été fondée,

- un Service d'inspection et de contrôle des Etablissements d'Enseignement du Bouddhisme a été créé,

- les programmes d'enseignement à l'Ecole Supérieure de Pâli et dans les Ecoles Elémentaires de Pâli ont été refondus en vue de permettre l'acquisition des connaissances plus approfondies,

- l'Ecole Supérieure de Pâli a été transformée en Lycée Bouddhique Preah Suramarit, et les Ecoles Elémentaires de Pâli en "Ecoles Primaires Bouddhiques".

## L'INSPECTION GÉNÉRALE DE L'ENSEIGNEMENT DU BOUDDHISME

www.elibraryofcambodia.org

Le Service d'Inspection et de contrôle des Etablissements d'Enseignement Supérieur, Secondaire et Primaire du Bouddhisme créé par Kret nº 341-NS du 20-6-55, est assuré par un Inspecteur Général choisi parmi les Râjâgana et nommé par Kret sur la proposition du Ministre des Cultes après l'avis du Chef des deux Ordres.

L'Inspecteur Général est assisté :

— de deux Inspecteurs Généraux adjoints choisis parmi les Professeurs de l'Enseignement Secondaire du Bouddhisme et nommés à la tête de chaque région d'inspection par Prakas du Ministre des Cultes et après l'avis du Chef des deux Ordres.

— des Inspecteurs provinciaux et des sous-Inspecteurs de Srok, — ces deux dernières fonctions étant confiées respectivement au Mékon et Anoukon.

Il est placé en outre, auprès de l'Inspecteur Général, un Conseiller technique.

Par Kret nº 728-NS du 28-11-55, le Vénérable HOUT-TATH, Proviseur du Buddhika Vidyalay Preah Suramarit, est nommé

Inspecteur Général de l'Enseignement du Bouddhisme du Royaume.

Le Budget National supporte toutes dépenses concernant le Service d'Inspection.

Des tournées d'inspection ont été régulièrement effectuées par le Vénérable Inspecteur Général dans les Ecoles Primaires Bouddhiques du Royaume.

L'inspection porte principalement sur :

— le niveau de l'enseignement donné dans chaque école et son bon fonctionnement,
— l'importance des classes,
— l'application des programmes d'enseignement,
— l'emploi des livres scolaires.

## L'ENSEIGNEMENT PRIMAIRE DU BOUDDHISME

www.elibraryofcambodia.org

Les Ecoles Primaires Bouddhiques, mises sur pied en 1933 et réorganisées par Kret nº 607-NS du 12 Décembre 1957, fonctionnent dans divers monastères de la Capitale et de l'Intérieur. L'Enseignement est actuellement donné dans 590 Ecoles à trois classes réunissant un effectif de 10.150 élèves.

L'effectif des Moines-Instituteurs s'élève en 1960-61 à 799, dont 212 diplômés du Lycée Bouddhique Preah Suramarit.

**Régime d'Etudes.**— L'Enseignement primaire est la base de l'Enseignement secondaire du Bouddhisme. Les disciplines fixées ainsi qu'il suit sont enseignées en langue nationale :

| | | |
|---|---|---|
| — Grammaire Pâli et Dhammapada. . | de 7 à 8 h | par semaine |
| — Vinay Buddhappannatti et Doctrine B. | 2 h | —id— |
| — Langue nationale : grammaire, orthographe, rédaction. . . . . . . . | de 4 à 6 h | —id— |
| — Calcul . . . . . . . . . . . . . . . | de 4 à 5 h | —id— |
| — Histoire du Cambodge. . . . . . . | 1 h | —id— |
| — Géographie du Cambodge . . . . . | 1 h | —id— |

— Sciences et Hygiène . . . . . . . . de 2 à 2h 30 —id—
— Instruction civique . . . . . . . . 1 h —id—
— Notions théoriques d'agriculture . . . 30 minutes —id—

La durée des études dans les Ecoles Primaires Bouddhiques est fixée à trois ans au bout desquels les élèves pourront se présenter à l'examen du « Certificat d'Etudes Primaires du Bouddhisme ».

Le régime des congés et vacances scolaires, comme dans tous les Etablissements d'enseignement du Bouddhisme du Royaume, est fixé comme suit : — les 7è, 8è, 14è et 15è jour de la lune croissante et de la lune décroissante du mois lunaire.

— Petites vacances : du 1er au 14e jour de la lune croissante du mois de Assoch.

— Grandes vacances : du 1er Mars au 30 Avril.

**Ouverture de l'Ecole Primaire Bouddhique**.— Celle-ci fait l'objet d'une demande formulée par le Chef du Monastère qui se charge de toute organisation matérielle nécessaire : local, mobilier, matériel d'enseignement etc...

www.elibraryofcambodia.org

**Personnel Enseignant**.— Toute nomination aux fonctions de Moines-Instituteurs dans les Ecoles Primaires Bouddhiques, est prononcée, sur proposition du Chau-Athicar, par Prakâsanîyabàtr (Brevet de nomination) de l'Inspecteur Général avec approbation du Ministre des Cultes. Les Moines-Instituteurs sont choisis parmi les Diplômés de l'Enseignement Secondaire du Bouddhisme, et parmi les Certifiés de l'Ecole Elémentaire de Pâli.

L'organisation générale et technique pour le bon fonctionnement de l'Enseignement Primaire du Bouddhisme est confiée à l'initiative du Ministre des Cultes.

Le progrès constaté depuis ces dernières années dans l'Enseignement Primaire du Bouddhisme est au-delà de ce qu'on pouvait prévoir. Plus de deux mille élèves sortent chaque année de ces Ecoles, pourvus du « Certificat d'Etudes Primaires du Bouddhisme », les titulaires du dit certificat peuvent, sur leur demande, se présenter au Concours d'entrée au Lycée Bouddhique Preah Suramarit, 180 places étant réservées chaque année.

# L'ENSEIGNEMENT SECONDAIRE DU BOUDDHISME

Le " LYCEE BOUDDHIQUE PREAH SURAMARIT " est l'unique Etablissement d'Enseignement Secondaire du Bouddhisme du Royaume, connu autrefois sous les dénominations d' " Ecole de Pâli " puis d' " Ecole Supérieure de Pâli ",

A chacune de ces appellations correspond une organisation spéciale.

## L'ECOLE DE PALI
( 1914 - 1921 )

En 1914, fut créée sous la Haute Tutelle de Sa Majesté Sisowath, l' " Ecole de Pâli " dont l'emplacement provisoire se trouvait dans l'enceinte de la Pagode Preah Kéo Morakât (Pagode d'Argent) à Phnom-Penh (Ordonnance Royale nº 85 du 24 Novembre 1914).

Un premier concours pour le recrutement de 5 professeurs avait eu lieu en Novembre 1914. Le premier concours d'entrée à l'Ecole de Pâli était ouvert en Février 1915 : 60 moines furent admis à suivre leurs études dans trois classes existantes, 1ère année, 2ème année, 3ème année, à raison de 20 élèves par classe.

www.elibraryofcambodia.org

La durée des études était fixée à trois ans.

Le programme d'enseignement comportait uniquement l'étude du Pâli et du Khmer : Grammaire pâlie, Traduction du Pâli en Khmer des textes du Dhammapadatthakathà ; du Mangalatthadipani, du Visuddhimagga, de l'Abhidhammattha Sangaha.

Un premier examen de sortie dit " Examen du Diplôme de Pâli " avait eu lieu en 1917 : 16 élèves furent admis avec le titre de " Maha ".

**Jusqu'en** 1921 : — l'Ecole de Pâli recevait chaque année par voie de concours 20 nouveaux élèves,

— le nombre de moines titulaires du Diplôme de l'Ecole de Pâli s'élevait à 45.

Cependant le programme d'enseignement ainsi conçu n'avait pas permis aux élèves une vision assez large pour la compréhension du Bouddhisme. De là, première réforme du régime d'études et du programme, et naissance de l'Ecole Supérieure de Pâli.

## L'ECOLE SUPERIEURE DE PALI

(1922 - 1955)

**Emplacement.**— L'Ecole de Pâli fut transférée en 1922 dans un vaste bâtiment construit pour l'abriter à côté de l'ex phsar-Suon (emplacement actuel du Ministère des Cultes et de l'Institut Bouddhique). Elle portait dès lors le nom d' " ECOLE SUPERIEURE DE PALI " (Ordonnance Royale nº 57 du 13 Avril 1922) et comptait 4 classes représentant 4 années d'études.

En 1925, elle avait dû céder ses locaux au profit de la " Bibliothèque Royale du Cambodge " nouvelle création, et se retirer à la Pagode d'Argent. C'est à partir de 1926 que l'Ecole Supérieure de Pâli revint occuper jusqu'à nos jours les locaux de l'Ecole Franco-Khmère de Phsar-Suon (l'Ecole de Phsar-Suon appelée ensuite Ecole du Palais, fut créée en 1916 et supprimée dès 1927).

www.elibraryofcambodia.org

**Administration.**— L'Ecole Supérieure de Pâli était placée sous le Haut Patronage de Sa Majesté le Roi du Cambodge.

Sous le Protectorat français, elle relevait directement du Ministère de l'Instruction Publique, ensuite du Ministère des Cultes, sous le contrôle du Résident Supérieur au Cambodge.

Etaient successivement nommés Directeurs de l'Ecole de Pâli :

— Preah Maha Vimaladhamma " Thong " : 1914-1927
— Preah Serey Sammattivong " Em " : 1927-1942
— Preah Buddhaghosachar " Chuon-Nath " : 1942-1948
(Chef de l'Ordre Mohanikay actuel)
— Preah Bodhivamsa " Huot-Tath " : depuis 1948
— Censeur : Preah Brahmamuni " Tep-Ou " : depuis 1942

## REGIME D'ETUDES - PROGRAMME.—

La durée des études est fixée à 4 années.

Plusieurs modifications ont été apportées dans l'établissement du programme pour mieux répondre aux fins poursuivies par l'Ecole Supérieure de Pâli : favoriser et développer les études du Bouddhisme par un enseignement rationnel des langues classiques et de toutes les connaissances indispensables à la compréhension des textes religieux.

Les matières enseignées, d'une façon générale, comprenaient :

1.— Langues classiques : Pâli, Sanskrit
2.— Langue et littérature khmère, religieuse et profane
3.— Histoire politique, religieuse et archéol. du Cambodge
4.— Histoire générale du Bouddhisme
5.— Fondement du Bouddhisme
6.— Géographie de l'Indochine et des pays voisins, notamment des pays Bouddhiques. Premiers éléments de géographie universelle - Extrême-Orient : Races, religions, évolution
www.elibraryofcambodia.org
7.— Langue française, vocabulaire courant, lecture expliquée, grammaire, exercice de traduction
8.— Arithmétique, Système métrique et Géométrie en français
9.— Histoire des religions
10.— Histoire politique et économique contemporaine
11.— Sciences naturelles et Hygiène en français (étudiées à partir de l'année 1952).

## CONCOURS ET EXAMEN.—

D'une façon générale, l'examen ou le concours comprenait des épreuves écrites et des épreuves orales suivantes :

### A.— Concours d'admission :

#### Epreuves écrites :

1.— Dictée cambodgienne
2.— Traduction en cambodgien d'un texte pâli

3 — Commentaire d'une prescription en pâli tirée du Dhammapadatthakatha

4 — Récit d'une épisode choisie dans le Dhammapadatthakatha.

**Epreuves orales** : (supprimées depuis la session de 1953)

1 — Grammaire pâlie
2 — Episode de la vie du Bouddha
3 — Histoire du Bouddhisme
4 — Vinaya.

Le concours d'admission était ouvert chaque année, compte-tenu du nombre de places fixé d'avance.

| | | | |
|---|---|---|---|
| De 1922 à 1927 : | par an | 25 | places |
| — 1928 à 1932 : | -id- | 30 | -id- |
| — 1933 - 1943 : | -id- | 35 | -id- |
| — 1944 - 1946 : | -id- | 40 | -id- |
| — 1947 - 1954 : | -id- | 100 | -id- |
| en 1955 : | -id- | 150 | -id- |

www.elibraryofcambodia.org

Le nombre de candidats inscrits chaque année au concours d'entrée était jusqu'en 1932 de 100 à 160. Depuis la création des Ecoles Primaires du Bouddhisme (1933), le nombre de présentés s'élevait de 200 à 2.000 environ par an, raison pour laquelle il y avait ouverture de 2 salles de classe de 1ère année de 1947 à 1954, et de 3 salles de classe de 1ère année de 1955 à 1960.

L'Ecole Supérieure de Pâli recevait également sans concours depuis 1940 vingt auditeurs libres (Laotiens et Cambodgiens de Cochinchine) par an. Depuis 1952, ceux-ci travaillent en qualité d'élèves officiels.

**Examen de sortie**.— A la fin de la quatrième année d'études, les élèves subissaient l'examen de sortie pour l'obtention du « Diplôme de l'Ecole Supérieure de Pâli ».

L'examen comportait des épreuves écrites et orales suivantes :

**Epreuves écrites :**

1.— Traduction d'un texte pâli en cambobgien
2.— Traduction en cambodgien d'un texte Sanskrit en devanagari
3.— Traduction d'un texte cambodgien en français
4.— Commentaire d'une prescription de l'Abhidhamma ou de Preah Vinaya
5.— Traduction d'un texte cambodgien en Pâli
6.— Rédaction en Pâli sur un sujet donné.

**Epreuves orales** (supprimées depuis 1954)

1.— Traduction et explication d'un texte Sanskrit en devanagari, transcription cambodgienne et latine
2.— Histoire religieuse et archéologique du Cambodge
3.— Préceptes moraux et bouddhiques
www.elibraryofcambodia.org
4.— Histoire des Religions
5.— Littérature khmère
6.— Géographie : Asie Orientale, Péninsule indochinoise
7.— Conversation française
8.— Exercice d'arithmétique
9.— Conversation en Pâli
10.— Histoire politique et économique contemporaine
11.— Education morale et civique.

Depuis la suppression des épreuves orales, les épreuves écrites comprenaient plusieurs matières (application du Kret nº 103-NS du 17 Mars 1952) :

**Au concours d'entrée** (de 1953 à 1955) : étaient ajoutées les épreuves de calcul et de rédaction khmère.
Total : 8 épreuves érites.

**Au Diplôme** (de 1954 à 1958) : 13 épreuves écrites.

Epreuves ajoutées : Rédaction française sur un sujet facile.

— Problème d'Arithmétique

— Questions de Sciences naturelles et d'hygiène.

**RÉSULTAT DES EXAMENS.—**

**Jusqu'en 1958.—** Le nombre de titulaires du « Diplôme de l'Ecole Supérieure de Pâli » s'élevait à 1.425; — des « Certificats d'assiduité » étaient délivrés à 56 auditeurs libres ayant terminé leur quatrième année d'études.

Dans l'ensemble, l'Ecole Supérieure de Pâli, par ses contacts avec l'Institut Bouddhique, a connu bien des progrès.

Des centaines de livres (Dictionnaire cambodgien — Tripitaka — livres ayant trait à l'histoire du Bouddhisme, à la littérature) ont pu paraître grâce à l'organisation de l'Ecole Supérieure de Pâli et le Cambodge a conquis une haute renommée pour sa culture religieuse.

www.elibraryofcambodia.org

Avec l'acquisition de l'Indépendance Nationale, une commission chargée d'étudier et d'élaborer un programme d'enseignement secondaire du Bouddhisme a été instituée.

L'Ecole Supérieure de Pâli transformée en « BUDDHIKA VIDYALAY PREAH SURAMARIT » (Lycée Bouddhique Preah Suramarit) par Kret nº 388-NS du 4 Juillet 1955, a son nouveau régime d'études et son nouveau programme.

## LE LYCÉE BOUDDHIQUE PREAH SURAMARIT

Le Lycée Bouddhique est placé sous le Haut Patronage de Sa Majesté le Roi. Sa réorganisation par Kret nº 265-NS du 8 Mai 1955, vise à :

— fortifier la pratique religieuse

— développer l'amour de la culture et de la civilisation nationales
— développer le sens de l'humain par l'enseignement de la culture et de la civilisation internationales
— assurer un épanouissement harmonieux de l'intelligence et favoriser la formation de la personnalité
— préparer les moines aux études supérieures du Bouddhisme.

## FONCTIONNEMENT ET PERSONNEL :

L'Etablissement est alimenté par le Budget de l'Etat et relève directement du Ministère des Cultes.

Le contrôle de fonctionnement de l'Etablissement est assuré par un Conseil d'Administration ainsi composé :

| | |
|---|---|
| — Le Ministre des Cultes ou son Délégué ...... | Président |
| — Le Délégué du Chef de la Secte Mohanikay .. | Memhre |
| — Le Délégué du Chef de la Secte Dhammayut. | -id- |
| — Le Proviseur du Lycée Bouddhique Preah Suramarit .................................. | -id- |
| — Trois Professeurs .......................... | -id- |
| — Un Professeur de l'Enseignement désigné par le Ministre de l'Education Nationale ........ | -id- |

www.elibraryofcambodia.org

Le Conseil d'Administration se réunit obligatoirement une fois par an après l'examen de sortie. Il examine les rétultats obtenus au cours de la dernière année scolaire, propose des revisions éventuelles des programmes ainsi que toutes mesures et directives jugées indispensables pour le bon fonctionnement de l'Etablissement.

La Direction de l'Etablissement est assurée par

un Proviseur : Preah Bodhivamsa HUOT-TATH
et un Censeur secondés par un Directeur d'Etudes et des Surveillants.

Les Personnel enseignant comprend :

— d'une part, des Professeurs religieux, — et laïcs du cadre

régulier, au nombre actuel de quinze, chargés de donner des cours de Pâli, de Sanskrit,de Khmer et d'Anglais,

— d'autre part, des Professeurs et Instituteurs de l'Enseignement National mis en service détaché au nombre actuel de quatre, chargés d'assurer des cours de Français, de Mathématiques, d'Histoire de Géographie, de Sciences Naturelles et d'Hygiène.

En raison de la pénurie actuelle du personnel enseignant du cycle secondaire, d'autres Professeurs sont appelés pour donner des cours rétribués de Mathématiques, de Physique et de Chimie dans les classes supérieures.

Enfin dans le cadre d'échanges culturels, des organismes étrangers ont bien voulu mettre à sa disposition des Professeurs pour l'enseignement de certaines disciplines.

— Un professeur d'Anglais, de la Fondation d'Asie.
— Deux Professeurs de Français, de la Mission Culturelle française, et un Professeur de Sanskrit, de l'Ambassade de l'Inde.

www.elibraryofcambodia.org

## RECRUTEMENT

Les nouveaux élèves sont recrutés par voie de concours chaque année parmi les moines titulaires de Certificat d'Etudes Primaires du Bouddhisme.

Le Concours d'admission ne comporte que des épreuves écrites suivantes :

1.— Traduction d'un texte Pâli en Cambodgien et questions
2.— Dictée cambodgienne avec ou sans questions ou Rédaction khmère
3.— Question de Vinaya ou Doctrine
4.— Problèmes sur les quatre opérations

## PROGRAMME D'ETUDES

Le programme est établi, compte tenu des objectifs ci-dessus fixés, selon les principes suivants :

— conserver intact le caractère traditionnel de l'enseignement : étude du Pâli et du Sanskrit qui constitue une base solide pour l'acquisition d'une connaissance approfondie de la langue et de la culture khmères

— améliorer le programme par introduction de nouvelles disciplines (algèbre, géométrie, physique, chimie, anglais) et par refonte du programme d'Histoire, de Géographie, de Sciences naturelles et d'Hygiène, de façon à donner un véritable enseignement secondaire

— employer la langue nationale comme langue véhicule dans l'enseignement de toutes les matières relevant du domaine temporel.

Ci-dessous le tableau des matières enseignées avec horaire hebdomadaire par classe :

| MATIERES | | HORAIRE par semaine | | | |
|---|---|---|---|---|---|
| | | 1ère Année | 2e Année | 3e Année | 4e Année |
| Langue classique | Pâli | 8 heures | 6 heures | 6 heures | 5 heures |
| | Sanskrit | | 3 heures | 3 heures | 3 heures |
| Langue Nationale | | 2 heures | 2 heures | 2 heures | 2 heures |
| Anglais | | 5 heures | 5 heures | 5 heures | 4 heures |
| Français | | 4 heures | 4 heures | 4 heures | 4 heures |
| Histoire | | 2 heures | 1 heure | 1 heure | 2 heures |
| Géographie | | 1 heure | 1 heure | 1 heure | 1 heure |
| Mathématiques | | 5 heures | 4 heures | 4 heures | 4 heures |
| Sciences | sciences naturelles et hygiène | 2 heures | 1 heure | 1 heure | 1 heure |
| | physique | | 2 heures | 1 heure | 1 heure |
| | chimie | | 1 heure | 1 heure | 1 heure |
| Instruction civique | | 1 heure | | | 1 heure |
| Connaissance générale | Histroire des Religions | | | 1 heure | |
| | Civilisation et Art khmers | | | | 1 heure |
| Total | | 30 heures | 30 heures | 30 heures | 30 heures |

www.elibraryofcambodia.org

## SANCTION DES ETUDES

Après la 4è Année, les études sont sanctionnées en cas de succès à l'examen final, par un " **DIPLOME D'ETUDES SECONDAIRES DU BOUDDHISME** "

L'examen ne comporte que des épreuves écrites suivantes :

1— Version ou Thème pâli

2— Version ou Thème Sanskrit

3— Version ou Thème anglais ou français

4— Dissertation sur la doctrine bouddhique (Preah Vinaya ou Abhidhamma)

5— Histoire - Géographie

6— Mathématiques

7— Sciences { Sciences Naturelles, Physique, Chimie }

Deux sessions d'examen sont ouvertes chaque année (Kret n° 206-CR du 24 Mai 1960).

www.elibraryofcambodia.org

## STATISTIQUE

(Effectif des élèves et résultats aux divers examens et concours depuis la réorganisation de l'Enseignement Secondaire du Bouddhisme).

| Année Scolaire | Nouveaux inscrits | Nombre de classes | Effectif des élèves | Diplôme d'Etudes Sec. du Bouddhisme | |
|---|---|---|---|---|---|
| | | | | Nombre de présentés | Admis |
| 1955 - 56 | 157 | 9 | 557 | | |
| 1956 - 57 | 150 | 10 | 610 | | |
| 1957 - 58 | 166 | 11 | 650 | | |
| 1958 - 59 | 174 | 12 | 666 | 147 | 97 |
| 1959 - 60 | 170 | 12 | 705 | 1ère session 196 | 112 |
| | | | | 2è — 79 | 12 |
| 1960 - 61 | 156 | 12 | 656 | 1ère session 218 | 160 |
| | | | | 2è — 53 | 2 |
| 1961 - 62 | 184 | 13 | 680 | | |

# CONCLUSION

L'enseignement du Bouddhisme ainsi réorganisé en trois cycles avec les programmes appropriés, marque un incontestable progrès.

La connaissance des sciences modernes, des cultures et des civilisations internationales vient renforcer le caractère scientifique et humanitaire contenu dans l'essence même du Bouddhisme.

Les titulaires du Diplôme d'Etudes Secondaires du Bouddhisme, s'ils ne sont pas admis à continuer leurs études à l'Université Bouddhique Preah Sihanouk Ràj, regagnent leurs monastères d'origine, assurant l'enseignement dans des Ecoles primaires bouddhiques pendant une période d'au moins un an. Grâce aux connaissances acquises pendant leurs quatre années d'études au Lycée Bouddhique Preah Suramarit, ces moines - instituteurs sont mieux préparés à leur rôle spirituel et social au milieu des fidèles habitués à leur soumettre toutes questions et leur demander conseils.

Le Bouddhisme, en prêchant la possibilité de transformation
www.elibraryofcambodia.org
de la nature humaine par l'enseignement de l'effort et de l'amour envers tous êtres vivants, a tellement pénètré les moines et les fidèles que des sacrifices de tous ordres dans le domaine éducatif religieux, ont été consentis pour le maintien des valeurs spirituelles du passé khmer et, par suite, de la paix.

www.elibraryofcambodia.org

www.elibraryofcambodia.org